កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY
ការិយាល័យទំនាក់ទំនង Tel: 023 882 990 ទូរសារ/ Fax: 023 882 656
ឆ្នាំទី៨ លេខ១៨៦៤ ថ្ងៃពុធ ទី០៤ ខែកុម្ភៈ ឆ្នាំ២០០៩ តំលៃ ១០០០ រៀល

# ខ្សែភាពយន្តរឿង "Dancing Across Borders" បញ្ជាក់អំពីការតស៊ូរបស់កូនខ្មែរ

**ក្រុងសៀមរាប** : ខ្សែភាពយន្តដែលមានចំណងជើងថា "Dancing Across Borders" ត្រូវបានបញ្ចាំងកាលពីរាត្រីថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៩ នៅសណ្ឋាគារសូហ្វីតែលរ៉ូយ៉ាល់អង្គរ ដែលរៀបចំឡើងដោយអង្គការមូលនិធិនិមិនកាល្អូស។ ពិធីនេះប្រព្រឹត្តទៅក្រោមវត្តមានលោក ស៊ូ ភិរិន្ទ អភិបាលខេត្តសៀមរាប និងភ្ញៀវទេសចរបរទេសជាច្រើនកុះករ។

លោកស្រីអាន់ ប៉ាស់ ជនជាតិអាមេរិកាំង និងជាអ្នកចូលចិត្តផ្នែករបាំបានឱ្យដឹងថា អ្នកស្រីបានមកទស្សនាប្រទេសកម្ពុជា ពិសេសនៅតំបន់ប្រាសាទអង្គរបានឃើញកុមារសុវណ្ណារ៉ា ហៅស៊ី កំពុងសំដែងរបាំនៅប្រាសាទព្រះខ័ន។ ក្រោយពីការវិលត្រឡប់ទៅប្រទេសអាមេរិកវិញ អ្នកស្រីមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីការសំដែងរបស់ស៊ី ហើយបានដក់ជាប់ក្នុងក្រអៅបេះដូងរបស់អ្នកស្រី។ អ្នកស្រីបានបន្តទៀតថា អ្នកស្រីបានស្នើសុំឱ្យអង្គការដែលរៀបចំរបាំនៅព្រះខ័ន ជួយទាក់ទងគ្រូរបស់ស៊ី នៅវត្តរាជបូព៌ា ដើម្បីឱ្យទៅសួរឪពុកម្តាយរបស់ស៊ី តើគាត់យល់ព្រមឱ្យកូនគាត់ទៅហាត់រៀនរបាំបាឡេនៅសហរដ្ឋអាមេរិកដែរឬទេ?។

នៅពេលជាមួយគ្នានេះដែរអ្នកស្រីបានទាក់ទងគ្រូរបាំបាឡេដែលល្បីល្បាញលើពិភពលោក គឺអ្នកស្រីអ៊ិល ហ្គា នៅទីក្រុងញូវយ៉ក ដើម្បីសួរគាត់ថា តើស៊ីអាចហាត់របាំបាឡេបានដែរឬទេ?។ អ្នកគ្រូបានប្រាប់ថា មានការលំបាកបន្តិចហើយ ពីព្រោះស៊ី មានអាយុ១៦ឆ្នាំទៅហើយ ហើយរបាំនេះចាប់ផ្តើមចូលហាត់រៀននៅអាយុ៦ឆ្នាំ។ ប៉ុន្តែអ្នកស្រីអាន់ ប៉ាស់ នៅតែមានអារម្មណ៍ថា ស៊ី ពិតជាអាចហាត់របាំបាឡេបាន។

អ្នកស្រីអាន ប៉ាស់ បានបញ្ជូនស៊ីទៅទីក្រុងញូវយ៉កប្រទេសអាមេរិក ដើម្បីបញ្ជាក់ពីសមត្ថភាពរបស់ "ស៊ី" ហើយអ្នកស្រីបានរៀបចំជួបអ្នកគ្រូអ៊ិល ហ្គា ដើម្បីបង្ហាត់របាំបាឡេដល់ស៊ី មួយទល់នឹងមួយ ព្រមទាំងគ្រូភ្លេងពីព្យាណូដោយម៉ឺងម៉ាត់ និងតឹងតែងបំផុត។ បន្ទាប់រយៈពេល

តទៅទំព័រ ឃ៣



លោកស៊ូ ភិរិន្ទ និងភ្ញៀវទេសចរជាតិនិងអន្តរជាតិចូលរួមទស្សនាខ្សែភាពយន្ត

## ខ្សែភាពយន្តរឿង ...

បាន២ ឬ៣ខែ អ្នកស្រីអ៊ិល ហ្គា បានវាយតំលៃថា សមត្ថភាពរបស់ស៊ី ក្នុងការហាត់របាំបាឡេអាចហាត់បាន ពីព្រោះស៊ី បានទទួលការហាត់របាំខ្មែរ តាំងពីក្មេងមកម្ល៉េះ ហើយកាយសម្បទាទន់ស្រាប់ គ្រាន់តែពិបាកត្រង់ថា ត្រូវសំរកខ្លួនពីក្បាច់ខ្មែរ មកក្បាច់បែបលោកខាងលិច។ ក្រៅពីម៉ោងហាត់ស៊ី ត្រូវឆ្លៀតពេលទៅរៀនភាសាអង់គ្លេស រហូតទទួលបានសញ្ញាបត្រជាភាសា។

បន្ទាប់ពីរយៈពេលបាន៥ឆ្នាំស៊ី ក៏បានទៅប្រឡងរបាំបាឡេជាគ្នាតអន្តរជាតិនៅទីក្រុងវៀរណាប្រទេសប៊ុលហ្គារី ហើយបានឈានចូលវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ ហើយបានហាត់រៀនបាឡេបន្តទៀតជាមួយគ្រូឈ្មោះពិជើបូល នៅ New York City Ballot។ ពេលនោះអ្នកគ្រូ និងលោកគ្រូមានការភ្ញាក់ផ្អើលនូវសមត្ថភាពរបស់ស៊ីដែលគំររកបានណាស់ក្នុង១០០នាក់ មានតែម្នាក់ប៉ុណ្ណោះ។ ម្ល៉េះហើយគេនាំគ្នាសរសើរអ្នកស្រីអាន ប៉ាស់ ដែលបានជ្រើសរើសម្នាក់នោះ គឺស៊ី និងឧបត្ថម្ភគ្រប់បែបយ៉ាង។

សព្វថ្ងៃស៊ី បានចូលហាត់ជាអ្នកអាជីពរបាំបាឡេនៅ Northwest Ballet អ្នកស្រីអាន ប៉ាស់ ចង់ផ្សព្វផ្សាយពីប្រវត្តិស៊ី ដែលចេញពីត្រកូលកសិករសុទ្ធសាធ រហូតដល់មានក្តីសង្ឃឹមថា នឹងបានល្បីល្បាញនៅលើឆាកអន្តរជាតិ ដើម្បីឱ្យសាធារណៈជនបានដឹង។ អ្នកស្រី អាន ប៉ាស់ បានផលិតខ្សែភាពយន្តមួយមានចំណងជើងថា "Dancing Across Borders" ដែលនិយាយពីប្រវត្តិ "ស៊ី" តាំងពីក្មេងនិងការខិតខំប្រឹងប្រែងហាត់រៀនរបស់គាត់។



លោកស្រីកន្លា វ៉ាវិនមិនការេត ជាប្រធានមូលនិធិនៃអង្គការមូលនិធិមិនកាអេត សំរាប់កម្ពុជា កំពុងបំពេញការអភិវឌ្ឍន៍បានឱ្យដឹងថា តាំងពីឆ្នាំ២០០០ ប្រជាជនក្រីក្រនៅស្រុកបន្ទាយស្រ៊ី ដែលមានប្រជាជនសរុបចំនួន២៥៤៨គ្រួសារ ដែលរស់នៅក្នុង១៤ភូមិ។ លោកស្រីបានបង្កើតសាលារបាំនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរបស់អង្គការចំងាយ២គីឡូម៉ែត្រពីប្រាសាទបន្ទាយស្រីរយៈពេល២ឆ្នាំកន្លងមកហើយ សព្វថ្ងៃមានសិស្សសរុប១២៣នាក់។ លោកស្រីបានអញ្ជើញលោកអភិបាលខេត្តសៀមរាប និងភ្ញៀវអន្តរជាតិព្រមទាំងអ្នកស្រីអាន ប៉ាស់ មកមើលខ្សែភាពយន្តដែលអ្នកស្រីអាន ប៉ាស់ ផលិតនៅសូហ្វីតែលរ៉ូយ៉ាល់អង្គរសៀមរាប ជាលើកទី២។ លោកស្រីបានដឹកនាំសិស្សដែលមានស្នាដៃក្នុងការរាំចំនួន៣៥នាក់មកទស្សនាខ្សែភាពយន្តនេះដែរ ហើយឡើងសំដែងលើឆាកជាលើកដំបូងនៅចំពោះមុខភ្ញៀវអន្តរជាតិចំនួនពាររបាំ។

លោកស៊ូ ភិរិន្ទ អភិបាលខេត្តសៀមរាបមានប្រសាសន៍ថា ក្នុងនាមអាជ្ញាធរខេត្ត សូមសរសើរពីស្នាដៃផលិតខ្សែភាពយន្តរបស់អ្នកស្រីអាន ប៉ាស់ និងនេះជ្រើសរើសអ្នកដែលមានទេពកោសល្យផ្នែករបាំបាឡេ។ ចាម សិទ្ធ

កម្ពុជាថ្មី ប្រចាំថ្ងៃ

KAMPUCHEA THMEY DAILY

ការិយាល័យទំនាក់ទំនង Tel: 023 882 990 ទូរសារ/ Fax: 023 882 656

ឆ្នាំទី៨ លេខ១៨៦៥ ថ្ងៃព្រហស្បតិ៍ ទី០៥ ខែកុម្ភៈ ឆ្នាំ២០០៩ តំលៃ ១000 រៀល


# សេចក្ដីកែតំរូវ

ក្រោយពីកាសែតកម្ពុជាថ្មីចេញផ្សាយលេខម្សិលមិញនូវអត្ថបទមួយដែលមានចំណងជើងថា "ខ្សែភាពយន្តរឿង Dancing Acroos Borders...."

ដែលនៅក្នុងអត្ថបទសរសេរថា "អង្គការមូលនិធិអឹនកាលូស" សូមកែមកថា "អង្គការមូលនិធិអិនការេត" វិញ ចំណែកកុមារសុវណ្ណារ៉ា សូមកែមកថា កុមារស សុវណ្ណារ៉ាហៅ "ស៊ី" និងពាក្យថា "សញ្ញាបត្រ" សូមកែមកថា "សញ្ញាបត្រភាសាអង់គ្លេស" វិញ ឯពាក្យថា New York City Ballot សូមកែមកថា New York City Ballet, និងពាក្យថា North west Ballet សូមកែមកថា នៅ Pacific North west Ballet វិញ និងតួលេខក្នុង១00នាក់សូមកែមកក្នុង១000នាក់វិញ។

បញ្ជាក់: ក្នុងនោះលោកស៊ី ភិរិន្ទបានសរសើរលោកជំទាវ កន្ធារ៉ាវីនអិនការេត ដែលបានជួយលើកស្ទួយនៅវប្បធម៌ខ្មែរដែលធ្លាប់មានឈ្មោះបោះសំឡេងនៅទូទាំងសកលលោក៕